00725395

E110

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
**ORIGINAL DOCUMENT/DOCUMENT ORIGINAL**
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 12 / 08 / 2011
ម៉ោង (Time/Heure) : 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# ដីកាកំណត់កាលបរិច្ឆេទសវនាការស្តីពី
# បញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង ធីរិទ្ធ
អៀង សារី
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS

ផាត់ ពៅសៀង
Diana ELLIS
សា សុវ៉ាន
Jaques VERGÈS
Philippe GRÉCIANO

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) ។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាដែលបានចេញដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ[1]។

**បានឃើញ** ដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១ (ឯកសារលេខ E62/3) ដែលបានចាត់តាំងសាស្ត្រាចារ្យ John CAMPBELL វេជ្ជបណ្ឌិតជំនាញខាងព្យាបាលថែទាំជំងឺមនុស្សចាស់នៅទីក្រុង Dunedin ប្រទេសណូវែលហ្សេឡង់ ជាអ្នកជំនាញ និងបានស្នើឱ្យអ្នកជំនាញរូបនេះធ្វើការវាយតម្លៃអំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទទាំងអស់ ដែលតវ៉ាអំពីកាយសម្បទារបស់ខ្លួនក្នុងការចូលរួមសវនាការ ឬលទ្ធភាពអង្គុយក្នុងសវនាការរយៈពេលយូរ និងបានស្នើសុំឱ្យរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងជនជាប់ចោទម្នាក់ៗ ដាច់ដោយឡែកពីគ្នា។

**កត់សម្គាល់ផងដែរថា** ជនជាប់ចោទ ខៀវ សំផន បានបដិសេធក្នុងការទទួលយកការវាយតម្លៃនេះ ហើយក្នុងពេលបច្ចុប្បន្ននេះ គាត់មិនតវ៉ាអំពីបញ្ហាកាយសម្បទារបស់គាត់ក្នុងការចូលរួមសវនាការនោះទេ[2] ។

**កត់សម្គាល់ផងដែរនូវ** របាយការណ៍របស់សាស្ត្រាចារ្យ CAMPBELL ពាក់ព័ន្ធនឹងជនជាប់ចោទ អៀង សារី នួន ជា និង អៀង ធីរិទ្ធ ដែលបានធ្វើឡើងបន្ទាប់ពីមានការវាយតម្លៃរបស់គាត់ទៅលើជនជាប់ចោទ និងការផ្ញើជូននូវរបាយការណ៍ទាំងនេះទៅភាគីពាក់ព័ន្ធនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ និងនៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ដាច់ដោយឡែកពីគ្នា អនុលោមតាមបែបបទដែលអង្គជំនុំជម្រះបានគូសបញ្ជាក់

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26 , សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9 ។

[2] ប្រតិចារឹក, ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ២០ (ភាសាអង់គ្លេស) (ដែលមានបញ្ជាក់អំពីបំណងរបស់ជនជាប់ចោទ ខៀវ សំផន ដែលពុំចង់ទទួលបានការពិនិត្យវេជ្ជសាស្ត្រ និងចេតនារបស់គាត់ចង់មានវត្តមាននៅក្នុងសវនាការទាំងអស់), ដីកាចាត់តាំងអ្នកជំនាញ, ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E62/3, កថាខណ្ឌ ៤។

នៅក្នុងឯកសារលេខ E62/3/10 ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ និង ឯកសារលេខ E62/3/10/4 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ ។

**បានឃើញ** សំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ ដែលបានស្នើសុំឱ្យដាក់នូវរបាយការណ៍ដែលបានរៀបចំដោយសាស្ត្រាចារ្យ CAMPBELL ទាក់ទងទៅនឹង អៀង សារី ជាប្រភេទឯកសារសាធារណៈ (ឯកសារលេខE62/3/9) ហើយដែលរបាយការណ៍នោះបានសន្និដ្ឋានថា ជនជាប់ចោទ អៀង សារី មានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហេតុដូច្នេះ ពុំតម្រូវឱ្យមានការកែប្រែកាលវិភាគសវនាការរបស់អង្គជំនុំជម្រះឡើយ ពាក់ព័ន្ធនឹងជនជនចោទរូបនេះ។

**កត់សម្គាល់ផងដែរ** នូវការប្រាស្រ័យទាក់ទងតាមរយៈសារអេឡិចត្រូនិករវាងមេធាវីការពារក្តី អៀង សារី និងអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ដែលក្នុងនោះមេធាវីការពារក្តី អៀង សារី បានបញ្ជាក់ថា មេធាវីមិនជំទាស់នឹងសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍របស់អ្នកជំនាញពាក់ព័ន្ធនឹងជនជាប់ចោទ អៀង សារី ឡើយ។ ប៉ុន្តែមេធាវីបានស្នើសុំឱ្យអនុវត្តតាមការណែនាំដែលមាននៅក្នុងរបាយការណ៍នោះ ពាក់ព័ន្ធនឹងការអង្គុយរបស់ជនជាប់ចោទនៅក្នុងបន្ទប់សវនាការ។

**យល់ឃើញថា** អង្គជំនុំជម្រះបានចាត់នូវវិធានការនានាដើម្បីអនុវត្តតាមការណែនាំដែលមាននៅក្នុងរបាយការណ៍ ដោយសហការជាមួយនឹងមេធាវីការពារក្តី អៀង សារី ហើយការពិភាក្សាលើបញ្ហានេះគឺកំពុងតែបន្តផងដែរ។

**ប្រកាសថា** អង្គជំនុំជម្រះពុំបានទទួលការតវ៉ាណាមួយឡើយទៅនឹងរបាយការណ៍របស់អ្នកជំនាញពាក់ព័ន្ធនឹងជនជាប់ចោទ អៀង សារី ឬការតវ៉ាអំពីកាយសម្បទារបស់ អៀង សារី ក្នុងការចូលរួមសវនាការ ឬលទ្ធភាពក្នុងការចូលរួមសវនាការ។

**បានឃើញ** នូវការជំទាស់របស់មេធាវីការពារក្តី នួន ជា ទៅលើរបាយការណ៍របស់អ្នកជំនាញពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១១ (ឯកសារលេខ E62/3/4/1) និងចម្លើយតបរបស់ការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១ (ឯកសារលេខ E62/3/4/2)។

**បានឃើញផងដែរ** នូវសេចក្តីសង្កេតរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ទៅលើរបាយការណ៍របស់អ្នកជំនាញពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ (ឯកសារលេខ

E62/3/6/1) និងចម្លើយតបរបស់ការិយាល័យសហព្រះរាជអាជ្ញាចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១១ (ឯកសារលេខ E62/3/6/2) ។

## ហេតុដូច្នេះសម្រេច

បើកសវនាការនៅថ្ងៃ ច័ន្ទ ទី ២៩ ខែ សីហា ឆ្នាំ ២០១១ និងថ្ងៃបន្តបន្ទាប់រហូតដល់ថ្ងៃ ពុធ ទី ៣១ ខែ សីហា ឆ្នាំ ២០១១ ប្រសិនបើចាំបាច់ ដើម្បីអនុញ្ញាតឲ្យមេធាវីការពារក្តី អៀង ធីរិទ្ធ និង នួន ជា សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរសំណួរដល់អ្នកជំនាញ និងបង្ហាញនូវអំណះអំណាងផ្សេងៗ អំពីការធ្វើសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍របស់អ្នកជំនាញទាក់ទងនឹងជនជាប់ចោទ នួន ជា និង អៀង ធីរិទ្ធ ។

**ផ្តល់ជូន** នូវព័ត៌មានបន្ថែមដូចខាងក្រោមទៅភាគី និងសាធារណជន ពាក់ព័ន្ធនឹងបែបបទនៃការធ្វើសវនាការនេះ៖

### សវនាការស្តីពីបញ្ហាកាយសម្បទាជនជាប់ចោទក្នុងការចូលរួមសវនាការ ថ្ងៃទី ២៩-៣១ ខែ សីហា ឆ្នាំ ២០១១

អង្គជំនុំជម្រះសូមបញ្ជាក់ថា អនុលោមតាមវិធាន ៧៩(៦) សវនាការលើបញ្ហានេះគឺធ្វើជាសាធារណៈឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ប៉ុន្តែ អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់អំពីភាពចាំបាច់ដែលត្រូវថ្លឹងថ្លែងរវាងសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការការពារនូវភាពសម្ងាត់ឯកជនរបស់ខ្លួនអំពីព័ត៌មានខាងផ្នែកវេជ្ជសាស្ត្រ ជាមួយនឹងសិទ្ធិរបស់សាធារណជនក្នុងការដឹងអំពីព័ត៌មានទាំងនេះ នៅពេលដែលការសម្រេចលើពាក្យសុំពាក់ព័ន្ធនឹងសប្បទារបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះកំពុងស្ថិតនៅក្នុងការពិចារណានៅឡើយ (ឯកសារលេខ E62/3/10)។

អង្គជំនុំជម្រះក៏បានដឹងផងដែរថា ទោះបីជារបាយការណ៍អ្នកជំនាញស្តីពីជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា លើកឡើងបញ្ហាផ្សេងៗគ្នា និងទាមទារឲ្យអង្គជំនុំជម្រះលើកយកមកពិចារណានៅក្នុងសវនាការដាច់ដោយឡែកពីគ្នាក្តី ក៏សេចក្តីសង្កេតជាច្រើនរបស់ក្រុមមេធាវីការពារក្តីទាំងពីរក្រុម ពាក់ព័ន្ធនឹងរបាយការណ៍អ្នកជំនាញនីមួយៗគឺមានភាពស្រដៀងៗគ្នា ឬដូចគ្នា (ឧទាហរណ៍ដូចជាពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៃការវាយតម្លៃ)។

ដើម្បីជៀសវាងការសួរសំណួរច្រាំដែលទៅដល់អ្នកជំនាញក្នុងអំឡុងសវនាការទាំងពីរនេះ អង្គជំនុំជម្រះនឹងបើកសវនាការរួមពាក់ព័ន្ធនឹងបញ្ហារបស់ក្រុមមេធាវីការពារក្ដីទាំងពីរក្រុម តែម្ដង។ អង្គជំនុំជម្រះសូមស្នើសុំឲ្យក្រុមមេធាវីការពារក្ដី នួន ជា និង អៀង ធីរិទ្ធ ធ្វើការសហការគ្នា និងធានាថា រាល់សំណួររួមទាំងអស់របស់ក្រុមមេធាវីការពារក្ដីទាំងពីរគឺត្រូវបានសួរទៅអ្នកជំនាញក្នុងលក្ខណៈមួយដែលមានការសម្របសម្រួលគ្នាជាមុននៅក្នុងសវនាការវគ្គដំបូង។ ដោយហេតុថា មេធាវីការពារក្ដី អៀង សារី មិនជំទាស់ទៅនឹងរបាយការណ៍របស់សាស្ត្រាចារ្យ CAMPBELL ពាក់ព័ន្ធនឹងកូនក្ដីរបស់ខ្លួននោះ ការចូលរួមរបស់មេធាវីការពារក្ដី អៀង សារី ពុំមែនជាការចាំបាច់នោះទេ ហើយអង្គជំនុំជម្រះក៏នឹងមិនអនុញ្ញាតឲ្យក្រុមមេធាវីការពារក្ដី អៀង សារី និយាយនៅក្នុងសវនាការនេះដែរ។ អង្គជំនុំជម្រះកត់សម្គាល់នូវសំណើរបស់មេធាវីការពារក្ដី អៀង សារី ដែលបានផ្ញើជូនចំពោះមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១ ដែលមេធាវីបានស្នើសុំចូលក្នុងសវនាការដើម្បីសង្កេតនូវកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះឯកភាពតាមសំណើសុំនេះសម្រាប់ផ្នែកនៃសវនាការរួម។

នៅចុងបញ្ចប់នៃសវនាការរួម អង្គជំនុំជម្រះនឹងបន្តសវនាការដោយឡែកមួយទៀត ដែលពាក់ព័ន្ធទៅនឹងបញ្ហារបាយការណ៍អ្នកជំនាញលើករណីជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា។ អង្គជំនុំជម្រះនឹងដំណើរការសវនាការ ដោយពិចារណាទៅលើរបាយការណ៍អ្នកជំនាញពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ (ដោយមានវត្តមានរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ការិយាល័យសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី) បន្ទាប់មកទៀត នឹងមានសវនាការមួយស្ដីពីបញ្ហានានាដែលបានលើកឡើងក្នុងរបាយការណ៍អ្នកជំនាញសម្រាប់ជនជាប់ចោទ នួន ជា (ដោយមានវត្តមានមេធាវីការពារក្ដី នួន ជា ការិយាល័យសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី)។

សវនាការទាំងអស់នឹងប្រព្រឹត្តទៅជាសាធារណៈ។ ចំណុចណាដែលភាគីយល់ថាសវនាការគួរធ្វើជាសម្ងាត់ ភាគីត្រូវស្នើសុំអង្គជំនុំជម្រះដោយផ្ទាល់មាត់។ សំណើទាំងនេះនឹងត្រូវស្ដាប់នៅក្នុងសវនាការជាសាធារណៈ ហើយអង្គជំនុំជម្រះនឹងឯកភាពប្រសិនបើ អង្គជំនុំជម្រះយល់ថា ផលប្រយោជន៍យុត្តិធម៌តម្រូវដូច្នេះ។ ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាតឲ្យសវនាការណាមួយបន្តប្រព្រឹត្តទៅជាសម្ងាត់ អង្គជំនុំជម្រះនឹងស្នើឲ្យភាគីយកបញ្ហាទាំងអស់មកដាក់រួមបញ្ចូលគ្នាសម្រាប់ពិចារណានៅក្នុងសវនាការសម្ងាត់ ដើម្បីធានាប្រសិទ្ធភាព និងកាត់បន្ថយការរំខានដល់សាធារណជន។

អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីថាបញ្ជីឯកសារសំខាន់ៗដែលពាក់ព័ន្ធមួយចំនួនដែលមាននៅក្នុងសំណុំរឿងគឺត្រូវបានប្រគល់ទៅឲ្យអ្នកជំនាញ និងបានប្រគល់ទៅឲ្យភាគីនៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១១ (ឯកសារ

លេខ E62/3/1)។ អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីថា ក្នុងពេលបច្ចុប្បន្ន អង្គជំនុំជម្រះកំពុងតែចងក្រងនូវឯកសារទាំងអស់ដែលអ្នកជំនាញបានយោងនៅក្នុងរបាយការណ៍របស់គាត់ទាក់ទងនឹងជនជាប់ចោទ នួន ជា និង អៀង ធីរិទ្ធ។ អង្គជំនុំជម្រះនឹងប្រគល់បញ្ជីឯកសារទាំងនេះជូនភាគីពាក់ព័ន្ធក្នុងពេលឆាប់ៗ ហើយឯកសារ ដែលភាគីពុំអាចពិនិត្យមើលបាននៅក្នុងសំណុំរឿងនៅពេលបច្ចុប្បន្ន នឹងត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន។ អង្គជំនុំជម្រះក៏បានស្នើសុំឱ្យលោកសាស្ត្រាចារ្យ កា ស៊ុនបូណាត ផ្តល់នូវរបាយការណ៍ដែលមានចុះហត្ថលេខារបស់គាត់ ហើយដែលរបាយការណ៍នោះគាត់បានប្រគល់ទៅឱ្យសាស្ត្រាចារ្យ Campbell ហើយអង្គជំនុំជម្រះក៏បានស្នើសុំឱ្យសាស្ត្រាចារ្យ កា ស៊ុនបូណាត ធ្វើការបញ្ជាក់លើរបាយការណ៍របស់គាត់ផងដែរ។ របាយការណ៍នេះ មានលេខឯកសារ E62/3/6.1 និង E62/3/6.2) ដែលត្រូវបានដាក់ទៅក្នុងសំណុំរឿងរួចហើយ។

ដើម្បីធានាថាកិច្ចនីតិវិធីប្រព្រឹត្តទៅបានឆាប់រហ័ស ការិយាល័យសហព្រះរាជអាជ្ញា មេធាវីការពារក្តី អៀង ធីរិទ្ធ មេធាវីការពារក្តី នួន ជា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវមានតំណាងលើសពីបួនរូបឡើយក្នុងសវនាការមួយលើកៗ (មេធាវីជាតិពីររូប និងមេធាវីអន្តរជាតិពីររូប)។

ប្រសិនបើពុំមានការបញ្ជាក់ណាមួយផ្សេងពីនេះ សវនាការទាំងនេះនឹងប្រព្រឹត្តទៅនៅម៉ោង ៩.00 នាទី ព្រឹក នៃថ្ងៃនីមួយៗ នៅក្នុងបន្ទប់សវនាការធំនៃ អ.វ.ត.ក។

អង្គជំនុំជម្រះសូមបញ្ជាក់ថា គោលបំណងនៃសវនាការទាំងនេះគឺធ្វើឡើងដើម្បីពិចារណា ត្រឹមបញ្ហាដែលមាននៅក្នុងរបាយការណ៍កោសល្យវិច័យរបស់សាស្ត្រាចារ្យ Campbell និងដើម្បីផ្តល់ឱកាសឱ្យភាគីលើកទឡ្ហីករណ៍តទល់ពាក់ព័ន្ធនឹងបញ្ហាទាំងអស់នោះតែប៉ុណ្ណោះ។ ជាលទ្ធផលនៃរបាយការណ៍នេះ អង្គជំនុំជម្រះនឹងចាត់តាំងអ្នកជំនាញបន្ថែមនាពេលឆាប់ៗខាងមុខ ដើម្បីបំពេញបន្ថែមលើគំនិតយល់ឃើញរបស់សាស្ត្រាចារ្យ Campbell។ អង្គជំនុំជម្រះនឹងជូនដំណឹងដល់ភាគី និងសាធារណជនបានដឹងបន្ថែមទៀតអំពីចំណាត់ការបន្តរបស់អង្គជំនុំជម្រះទាក់ទងនឹងអ្នកជំនាញបន្ថែមនៅពេលសមស្របខាងមុខនេះ។

ភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER · CHAMBRE DE PREMIÈRE INSTANCE · ECCC

និល ណុន